- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ច

**សំរេច**

**មាត្រា ១ :** ត្រូវបានតែងតាំងមុខតំណែង ជូនចំពោះ ៖

លោក **នួច សាខន** ជាទីប្រឹក្សាផ្ទាល់ ឯកឧត្តម **អ៊ុង ផន** ទទួលបន្ទុកកិច្ចការសំរបសំរួល ជាមួយ កងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ និងសាមីខ្លួន ត្រូវ អនុវត្តន៍អនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

## ២ - សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦

**សេចក្តីសំរេចលេខ ២២ សសរ.**

**ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីដោះស្រាយ**

**ប្រគល់បរិវេណបុរីកីឡាមកអោយធ្វើការជួសជុល**

**រាជរដ្ឋាភិបាលកម្ពុជា**

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
– បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
– ផ្អែកតាមការចាំបាច់

**សំរេច**

**ប្រការ ១** : ការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីដោះស្រាយប្រគល់បរិវេណប្ញីកីឡាមកធ្វើការជួសជុល ដែលមានសមាសភាពដូចតទៅ ÷

| | | |
|---|---|---|
| ១_ឯកឧត្តម **ហុក ឡងឌី** | អគ្គនាយកនគរបាលជាតិ | ប្រធាន |
| ២_ឯកឧត្តម **ពូ ដារ៉ានី** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៣_ឯកឧត្តម **ខួង ម៉េងហ៊ាន** | អភិបាលរងរាជធានីភ្នំពេញ | អនុប្រធាន |
| ៤_ឧត្តមសេនីយ៍ **ឈុំ ស៊ីណូ** | ប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈនៃក្រសួងមហាផ្ទៃ | សមាជិក |
| ៥_ឧត្តមសេនីយ៍ត្រី **លី យីម៉ុន** | ប្រធាននាយកដ្ឋានអធិការកិច្ចនៃ ក្រសួងការពារជាតិ | សមាជិក |
| ៦_លោក **សូ សាម្មុត** | សមាជិកគណៈកម្មការជួសជុលប្ញីកីឡា | សមាជិក |
| ៧_លោក **សៀង ម៉េងស្រ៊ុន** | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៨_លោក **សាម ម៉ុនហេង** | តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |

**ប្រការ ២** : គណៈកម្មការនេះ មានភារកិច្ចដោះស្រាយប្រគល់បរិវេណព្រមទាំងអគារទាំងឡាយនៃ ប្ញីកីឡាទៅអោយគណៈកម្មការជួសជុលប្ញីកីឡាដើម្បីធ្វើការជួសជុលក្នុង ក្របខ័ណ្ឌជំនួយឧបត្ថម្ភរបស់ចិន ។

គណៈកម្មការនេះ ត្រូវធ្វើការងារដូចខាងក្រោមនេះ

- ស្រាវជ្រាវសង់ស្ថិតិប្រភេទអ្នកដែលរស់នៅក្នុងប្ញីកីឡា តាមអង្គភាព និង តាមដំណាក់កាលនៃវេលាទីមួយៗ អោយបានពិតប្រាកដ
- ដោះស្រាយបញ្ហាសំណង់អនាធិតេយ្យ
- ដោះស្រាយបញ្ហាទីតាំងដែលជួលអោយទូរទូស្សន៍ប៉ុស្តិ៍លេខ ៥
- លើកគំរោងថវិកាសំរាប់ដោះស្រាយក្នុងកិច្ចការនេះ
- លើកវិធានការដោះស្រាយ និងសំណូមពរក្នុងកិច្ចប្រតិបត្តិការយកទីតាំង ប្ញីកីឡាមកធ្វើការជួសជុលដើម្បី សុំយោបល់សំរេចពីរាជរដ្ឋាភិបាល
- ធ្វើរបាយការណ៍សរុបអំពីលទ្ធផលការងាររបស់គណៈកម្មការជូនរាជរដ្ឋាភិបាល

**ប្រការ ៣** : គណៈកម្មការនេះ មានសិទ្ធិរៀបចំក្រុមការងារសំរាប់ប្រតិបត្តិក្នុងការប្រគល់ទីតាំងជាជំហាន ទៅអោយគណៈកម្មការជួសជុលប្ញីកីឡាអោយបានយ៉ាងឆាប់ទាន់ពេលវេលា ។

**ប្រការ ៤** : សមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន

**ប្រការ ៥** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ និងឯកឧត្តមអស់លោកដែលមានឈ្មោះក្នុងប្រការ ១ ត្រូវទទួលអនុវត្តតាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

**ប្រការ ៦** : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសំរេចនេះត្រូវទុកជានិរាករណ៍ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |